ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ០០៣......ឧវបវ......ម.ប.វ.ន......ភ.ខ.ខ.ប

# សេចក្តីណែនាំ

## ស្តីពី

## ការពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តអាជ្ញាប័ណ្ណផលិតនិងជួសជុលឧបករណ៍មាត្រាសាស្ត្រ

បច្ចុប្បន្នមានក្រុមហ៊ុន សហគ្រាសចំនួន១១ (ដូចមានភ្ជាប់ជូនក្នុងបញ្ជីក្រុមហ៊ុន សហគ្រាសដែលមានអាជ្ញាប័ណ្ណផលិតនិងជួសជុលឧបករណ៍មាត្រាសាស្ត្រទទួលស្គាល់ជាផ្លូវការ ដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍) បាននឹងកំពុងដំណើរការអាជីវកម្ម សេវាកម្ម លើការផលិតនិង/ឬជួសជុលឧបករណ៍មាត្រាសាស្ត្រ រួមមានជញ្ជីងតោននិងជញ្ជីងគ្រប់ប្រភេទ(ស្វ័យប្រវត្តិនិងមិនស្វ័យប្រវត្តិ) កុងទ័រទម្ងន់ស៊ីទែនគ្រប់ប្រភេទ ឧបករណ៍ចែកចាយឥន្ទនៈ(ប្រេងឥន្ទនៈនិងហ្គាសLPG) និងបានចូលរួមគោរពអនុវត្តត្រឹមត្រូវដូចមានចែងក្នុងជំពូកទី៩ មាត្រា ៣៤ ៣៥ និង៣៦ នៃច្បាប់ស្តីពីមាត្រាសាស្ត្រ។ ជាមួយគ្នានេះ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ពិនិត្យឃើញថាមានក្រុមហ៊ុន សហគ្រាសមួយចំនួនដែលកំពុងដំណើរការអាជីវកម្ម សេវាកម្មលើការផលិតនិង/ឬជួសជុលឧបករណ៍មាត្រាសាស្ត្រ ពុំមានអាជ្ញាប័ណ្ណដែលទទួលស្គាល់ជាផ្លូវការដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។

ក្នុងគោលបំណងលើកកម្ពស់ការចូលរួមលើការអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រឲ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពក្នុងសកម្មភាពពាណិជ្ជកម្មដល់អ្នកផ្គត់ផ្គង់និងអ្នកប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សូមធ្វើការណែនាំដូចខាងក្រោម៖

១- ក្រុមហ៊ុន សហគ្រាស ដែលពុំទាន់មានអាជ្ញាប័ណ្ណផលិតនិង/ឬជួសជុលឧបករណ៍មាត្រាសាស្ត្រ ឬ មានអាជ្ញាប័ណ្ណដែលហួសសុពលភាព ត្រូវមកស្នើសុំអាជ្ញាប័ណ្ណ ឬបន្តអាជ្ញាប័ណ្ណនៅច្រកចេញចូលតែមួយរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលមានអាសយដ្ឋាននៅអគារលេខ ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ, ទូរស័ព្ទលេខ តេលេក្រាម៖ ០៩៩ ៤៧០ ០៤២ និង០៩៧ ៩៧០ ២០ ៥៥ អ៊ីម៉ែល៖ows.nmc@misti.gov.kh ចាប់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ រៀងរាល់ម៉ោងធ្វើការ។

២- ក្រុមហ៊ុន សហគ្រាស ដែលមានអាជ្ញាប័ណ្ណផលិតនិងជួសជុលឧបករណ៍មាត្រាសាស្ត្រ ត្រូវបន្តសហការជាមួយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិក្នុងការអនុវត្តឱ្យបានត្រឹមត្រូវ តាមច្បាប់ស្តីពីមាត្រាសាស្ត្រនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៣- ក្រុមហ៊ុន សហគ្រាស ដែលពុំទាន់មានអាជ្ញាប័ណ្ណ និងកំពុងដំណើរការអាជីវកម្មលើការផលិតនិង/ឬជួសជុលឧបករណ៍មាត្រាសាស្ត្រ ហើយមិនបានមកស្នើសុំអាជ្ញាប័ណ្ណ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា



៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

និងនវានុវត្តន៍ នឹងអនុវត្តតាមច្បាប់ស្តីពីមាត្រាសាស្ត្រដូចមានចែងក្នុងជំពូកទី១០ មាត្រា៤២ ដោយត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ៥.០០០.០០០(ប្រាំលាន)រៀល ក្នុងករណីមិនរាងចាលត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

ទទួលបានសេចក្តីណែនាំនេះ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សង្ឃឹមថាលោក លោកស្រី ជាម្ចាស់ក្រុមហ៊ុន សហគ្រាស នឹងចូលរួមអនុវត្តសេចក្តីណែនាំនេះឱ្យបានពេញលេញ និងមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ 

ថ្ងៃ ព្រហ ១៣រោច ខែ កត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហែម វណ្ណឌី**

**<u>ចម្លងជូន៖</u>**

- ក្រសួងមហាផ្ទៃ
- រដ្ឋបាលរាជធានី-ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- គ្រប់មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី-ខេត្ត
  *"ដើម្បីផ្សព្វផ្សាយបន្ត និងសហការអនុវត្ត"*
- ឯកសារ កាលប្បវត្តិ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry Science Technology &Innovation
មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
National Metrology Canter

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

## បញ្ជីក្រុមហ៊ុន សហគ្រាស
## ដែលមានអាជ្ញាប័ណ្ណផលិត និងជួសជុលឧបករណ៍មាត្រាសាស្ត្រទទួលស្គាល់ជាផ្លូវការពី ម.ម.ជ

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | Company Name | អាសយដ្ឋាន | ឈ្មោះអ្នកតំណាង | លេខទូរស័ព្ទ | អ៊ីម៉ែល |
|---|---|---|---|---|---|---|
| ១ | សុខ គង់ អាហារណែ នីហារណែ | SOK KONG IMPORT EXPORT CO.,LTD. | ផ្ទះលេខ២២ ផ្លូវក្រមួនសរ សង្កាត់ផ្សារថ្មីII ខណ្ឌដូនពេញ រាជធានីភ្នំពេញ | លោក ឡៅ ចេង ហេង | ០២៣ ៧២៤ ១៤៣ | info@sokimex.com.kh |
| ២ | អិម ប៊ី អេ អ៊ិនជីនារីង& ខនស្រ្តាក់សិន(ខេមបូឌា) | MBA Engineering & Construction (Cambodia) Co.,Ltd | ផ្ទះលេខ២៦៩សេ ផ្លូវ ៣៦០ ភូមិ២ សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ | លោក វ៉ាចធាតិត វ៉ាសុណាន់ | ០២៣ ២១១ ០៤៩ | info@mbaengcambodia.com |
| ៣ | អាសូស៊ីអិត អេសហ្វល ប្រូដាក់គ្រុប | ASSOCIATE ASPHAL PRODUCTS GROUP CO.,LTD | ផ្ទះលេខA១១ ផ្លូវ២៧១ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ | ឧកញ៉ា ឈិន កេន | ០១៧ ៦៦៦ ៨៨៩ | truckscale@aapgroup.com.kh |
| ៤ | អេស 3 វីត្រេឌីង គ្រុប | S 3 V Trading Group Co., Ltd | ផ្ទះលេខ១៩១ ផ្លូវ ២០០៤ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ | លោក វ៉ា សុជាតិ | ០១២ ៩២១ ៩៩១ | s3vgroup@gmail.com |
| ៥ | សួស្តី វើក ភីធីអ៊ី អិលធីឌី | SOUSDEY WORKS PTE., LTD | ផ្ទះលេខ១០៣៨ ផ្លូវ១២ BT ភូមិសន្សំកុសល៤ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ | លោក គ្រិស អ៊ឹង | ០៧៨ ២២២ ៩៣៦ | samnang@sdworks.com.kh |
| ៦ | ខេមស៊ីសអ៊ិនជីនារីង | CAMSYS ENGINEERING CO., LTD | ផ្លូវជាតិ៦A ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ | លោកស្រី ធ ចេង | ០៦១ ៧៦៦ ៦៩៩ | ken@camsys.com.kh |
| ៧ | ខេអេសអរិន អ៊ីមផត & អិចផត ឯ.ក | KSRN Import & Export Co., Ltd | ផ្ទះលេខ១៦ ផ្លូវP-17 ក្រុម៧ ភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ | លោក គីម សារិន | ០៨៩ ៧៧៧ ៧៧៦ | kimsarin36@gmail.com |
| ៨ | អេស ប៊ី ស៊ី អេច សឹលូសិន ឯ.ក | SBCH SOLUTION CO., LTD | ផ្ទះលេខ៦១០ ផ្លូវ៣៧១ ភូមិត្នោតជ្រុំ២ សង្កាត់បឹងទំពុនទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ | លោក ឈិត សម្បត្តិ | ០៧០ ៣៣៣ ៣៩២ | sambath@sbch.com.kh |
| ៩ | សិប្បកម្មផ្គុំតំឡើងជញ្ជីងអេឡិចត្រូនិច និងជញ្ជីងថ្លឹង ថៅយន្ត គ្រាក់ ស្កេល | Sepakam Phkom Tomlerng Chonhching Electronic Nerng | ភូមិស្ពឹកខ្ញុំ ឃុំផ្ទះរុង ស្រុកតាំលោសែនជ័យ ខេត្តពោធិ៍សាត់ | លោក ទឹម ប៊ុនថេង | ០៦៩ ២៧០ ០០៣ | buntang.giff@gmail.com |

| | | | | | | |
|---|---|---|---|---|---|---|
| | | Chonhching Thlerng Rothyon Truck Scales | | | | |
| ១០ | មេត្រូឡូជី អ៊ិនស្ត្រូម៉ិន ថេសធីង សឺធីហ្វីខេសិន ឯក | METROLOGY INSTRUMENT TESTING CERTIFICATION CO., LTD | ផ្ទះលេខ២២៩ ផ្លូវ ៣០៧ ភូមិ១៣ សង្កាត់បឹងកេងកងទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ | លោកស្រី ផូ សុផាន | ០១១ ៥៦៩ ៥៧៩ | ou_socheata@yahoo.com |
| ១១ | សិប្បកម្មតំឡើង និងជួសជុលជញ្ជីងថ្លឹងរថយន្ត ហ៊ា ផល្លី | HEAR PHALLY TRUCK SCALE INSTALLATION AND REPAIR SERVICES | ក្បាលដី៥ ផ្ទះលេខ២៦៧៨ ភូមិលំទងថ្មី ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ | លោក ប៊ួយ ផល្លី | ០៩៧ ៥៩៩ ៩៥ ៩៥ | bouy.phally816@gmail.com |